Australian Government
Services Australia

KHMER

# Income Apportionment (ការបែងចែកប្រាក់ចំណូល) គ្រោងការណ៍ដំណោះស្រាយ

## ព័ត៌មានអំពីការទូទាត់ប្រាក់តែមួយដងគត់សម្រាប់បំណុលនានាដែលរងផលប៉ះពាល់ដោយ income apportionment

ប្រសិនបើអ្នកមានបំណុលដែលអាចនឹងរងផលប៉ះពាល់ដោយ income apportionment អ្នកអាចដាក់ពាក្យសុំ income apportionment គ្រោងការណ៍ដំណោះស្រាយ (គ្រោងការណ៍ដំណោះស្រាយ)។ អ្នកអាចពិនិត្យមើលថាតើអ្នកមានសិទ្ធិទទួលបានឬអត់នៅទំព័រ 2 នៃឯកសារនេះ។

បំណុលគឺជាប្រាក់ណាមួយដែលអ្នកត្រូវសងមកយើងវិញ។

អ្នកអាចដាក់ពាក្យសុំបានចាប់ពីថ្ងៃទី 30 ខែមករា ឆ្នាំ 2026 រហូតដល់ថ្ងៃទី 29 ខែមករា ឆ្នាំ 2027។

## តើអ្វីទៅ income apportionment?

យើងបានប្រើ income apportionment ដើម្បីបែងចែកប្រាក់ចំណូលការងាររបស់អតិថិជនឱ្យស្មើៗគ្នានៅពេញអំឡុងពេលរាយការណ៍ប្រចាំសប្ដាហ៍ 2 ឬច្រើនជាងនេះរបស់ Centrelink ។ យើងបានធ្វើការបែងចែកនេះ តែនៅពេលណាចំណុចទាំងពីរខាងក្រោមនេះអនុវត្តប៉ុណ្ណោះ៖

- អំឡុងពេលនៃការរាយការណ៍Centrelink របស់អ្នក មិនបានសម្របជាមួយនឹងអំឡុងពេលប្រាក់ខែការងាររបស់អ្នក។
- យើងមិនមានព័ត៌មានអំពីថ្ងៃដែលអ្នកធ្វើការ ឬចំនួនប្រាក់ដែលអ្នករកបានរៀងរាល់ពីរសប្ដាហ៍របស់Centrelink។

យើងផ្អែកលើអត្រាការទូទាត់ប្រាក់របស់អ្នក លើប្រាក់ចំណូលសរុបដែលអ្នកបានរាយការណ៍នៅទូទាំងអំឡុងពេលពីរសប្ដាហ៍នោះ។

ចាប់តាំងពីថ្ងៃទី 7 ខែធ្នូ ឆ្នាំ 2020 មក អ្នកគ្រាន់តែរាយការណ៍អំពីប្រាក់ចំណូលដែលបង្ហាញនៅលើលិខិតបៀវត្សរ៍របស់អ្នក នៅក្នុង ពីរសប្ដាហ៍ដូចគ្នាដែលអ្នកទទួលបានប្រាក់ឧបត្ថម្ភពី Centrelink ប៉ុណ្ណោះ។

នេះមានន័យថា យើងមិនចាំបាច់បែងចែកប្រាក់ចំណូលរបស់អ្នកពេញមួយសប្ដាហ៍ ដើម្បីគណនាអត្រាការប្រាក់របស់អ្នកសម្រាប់ប្រាក់ចំណូលដែលទទួលបានក្រោយថ្ងៃទី 7 ខែធ្នូ ឆ្នាំ 2020 នោះទេ។

នៅថ្ងៃទី 5 ខែធ្នូ ឆ្នាំ 2025 ច្បាប់បានចូលជាធរមាន ដើម្បីធ្វើសុពលភាពការប្រើប្រាស់ income apportionment។ នេះមានន័យថា បំណុលសម្រាប់ប្រាក់ចំណូលដែលរកបានមុនថ្ងៃទី 7 ខែធ្នូ ឆ្នាំ 2020 នឹងមិនត្រូវបានគណនាឡើងវិញទេ ហើយប្រហែលជាត្រូវសងវិញ។

# តើអ្វីទៅគ្រោងការណ៍ដំណោះស្រាយ?

គ្រោងការណ៍ដំណោះស្រាយផ្តល់សំណងដល់ប្រជាជន ដើម្បីទទួលស្គាល់ថា income apportionment មិនបំពេញតាមតាមច្បាប់សន្តិសុខសង្គមនៅពេលនោះ។

គ្រោងការណ៍ដំណោះស្រាយគឺមានសម្រាប់មនុស្សដែលបំណុលប្រាក់ចំណូលការងារត្រូវបានប៉ះពាល់ដោយ income apportionment នៅចន្លោះថ្ងៃទី 20 ខែកញ្ញា ឆ្នាំ 2003 និងថ្ងៃទី 6 ខែធ្នូ ឆ្នាំ 2020។

អ្នកត្រូវដាក់ពាក្យសុំដើម្បីមានសិទ្ធិទទួលបានការទូទាត់ប្រាក់តែមួយដងគត់រហូតដល់ទៅ $600។ ប្រសិនបើអ្នកមានបំណុលដែលមានសិទ្ធិទទួលលើសពីមួយ អ្នកអាចស្នើសុំការទូទាត់ប្រាក់សម្រាប់បំណុលនីមួយៗ។

ចំនួនប្រាក់ដែលអ្នកអាចទទួលបាន នឹងអាស្រ័យលើតម្លៃសរុបនៃបំណុលនីមួយៗនៅត្រឹមថ្ងៃទី 30 ខែមករា ឆ្នាំ 2026។ ប្រសិនបើអ្នកបានបង់សងបំណុលមួយចំនួនរួចហើយ វានឹងមិនប៉ះពាល់ដល់ចំនួនប្រាក់សំណងលើដំណោះស្រាយរបស់អ្នកទេ។

| តម្លៃបំណុលសរុប | ចំនួនប្រាក់សំណងលើដំណោះស្រាយ |
|---|---|
| តិចជាង $200 | តម្លៃបំណុលពេញលេញ |
| $200 – $1,999 | $200 |
| $2,000 - $4,999 | $400 |
| $5,000 ឬច្រើនជាងនេះ | $600 |

ប្រាក់សំណងលើដំណោះស្រាយនឹងមិនត្រូវជាប់ពន្ធទេ ហើយនឹងមិនត្រូវបានរាប់បញ្ចូលថាជាប្រាក់ចំណូលសម្រាប់ប្រាក់ឧបត្ថម្ភរបស់រដ្ឋាភិបាលឡើយ។

# តើខ្ញុំដឹងដោយរបៀបណា ថាខ្ញុំអាចទទួលបានប្រាក់សំណងលើដំណោះស្រាយឬអត់?

អ្នកអាចមានសិទ្ធិទទួលគ្រោងការណ៍ដំណោះស្រាយ ប្រសិនបើចំណុចទាំងអស់ខាងក្រោមអនុវត្តះ

- បំណុល Centrelink របស់អ្នកគឺយ៉ាងហោចណាស់មួយផ្នែកសម្រាប់រយៈពេលចន្លោះពីថ្ងៃទី 20 ខែកញ្ញា ឆ្នាំ 2003 ទៅថ្ងៃទី 6 ខែធ្នូ ឆ្នាំ 2020 ហើយទាក់ទងនឹងប្រាក់ចំណូលពីការងារ។
- បំណុលរបស់អ្នកត្រូវបានប៉ះពាល់ដោយ income apportionment និងបានបង្កើនមុនថ្ងៃទី 5 ខែធ្នូ ឆ្នាំ 2025
- អ្នកមិនត្រូវបានកាត់ទោស និងរកឃើញថាមានកំហុសពីការបោកបន្លំសម្រាប់បំណុលរបស់អ្នកទេ

- បំណុលរបស់អ្នកមិនត្រូវបានលើកលែងទាំងស្រុង ឬកំណត់ទៅជាសូន្យមុនថ្ងៃទី 30 ខែមករា ឆ្នាំ 2026។

អ្នកនៅតែអាចទទួលបានប្រាក់សំណងលើដំណោះស្រាយ ទោះបីជាអ្នកបានបង់សងបំណុលមួយផ្នែក ឬចំនួនពេញលេញក៏ដោយ។

អ្នកអាចពិនិត្យមើលថាតើបំណុលរបស់អ្នកត្រូវបានប៉ះពាល់ដោយ income apportionment ហើយថាអ្នកអាចទទួលបានប្រាក់សំណងលើដំណោះស្រាយឬអត់។

អ្នកអាចធ្វើដូច្នោះបានដោយប្រើគណនីអនឡាញ Centrelink របស់អ្នក តាមរយៈ myGov ឬ 3>កម្មវិធីទូរសព្ទ Express Plus Centrelink app ហើយធ្វើតាមជំហានទាំងនេះ៖

1. ចូលទៅកាន់សេវាកម្ម Money You Owe (ប្រាក់ដែលអ្នកជំពាក់)។
2. ចុចប៊ូតុង 'Apply for Resolution Scheme' ('ដាក់ពាក្យសុំ គ្រោងការណ៍ដំណោះស្រាយ')។
3. ប្រសិនបើអ្នកមានបំណុលដែលអាចមានសិទ្ធិទទួល វានឹងបង្ហាញនៅទីនេះ។

ប្រសិនបើអ្នកមិនមាន myGov ឬបានភ្ជាប់គណនីអនឡាញCentrelink សូមទូរសព្ទមកយើងតាមលេខ **1800 560 870**។ អ្នកក៏គួរទូរសព្ទទៅលេខនេះផងដែរ ប្រសិនបើអ្នកមិនឃើញបំណុលដែលបានរាយបញ្ជី ដែលអ្នកគិតថាគួរមានសិទ្ធិទទួល។

# តើខ្ញុំត្រូវដាក់ពាក្យសុំគ្រោងការណ៍ដំណោះស្រាយដោយរបៀបណា?

អ្នកអាចដាក់ពាក្យសុំគ្រោងការណ៍ដំណោះស្រាយបានចាប់ពីថ្ងៃទី 30 ខែមករា ឆ្នាំ 2026 រហូតដល់ថ្ងៃទី 29 ខែមករា ឆ្នាំ 2027។

អ្នកអាចដាក់ពាក្យសុំគ្រោងការណ៍ដំណោះស្រាយតាមអនឡាញ ឬតាមទូរសព្ទ។

ដើម្បីដាក់ពាក្យតាមអនឡាញ អ្នកនឹងត្រូវប្រើគណនីអនឡាញ Centrelink របស់អ្នក តាមរយៈ myGov ឬ 3>កម្មវិធីទូរសព្ទ Express Plus Centrelink app ហើយធ្វើតាមជំហានទាំងនេះ៖

1. ចូលទៅកាន់សេវាកម្ម Money You Owe (ប្រាក់ដែលអ្នកជំពាក់)។
2. ចុចប៊ូតុង 'Apply for Resolution Scheme' ('ដាក់ពាក្យសុំ គ្រោងការណ៍ដំណោះស្រាយ')។
3. ជ្រើសរើសបំណុលដែលអ្នកចង់ឱ្យមានការពិចារណាសម្រាប់ប្រាក់សំណងលើដំណោះស្រាយ។

ប្រសិនបើអ្នកត្រូវការជំនួយ ឬចង់ដាក់ពាក្យសុំតាមទូរសព្ទ អ្នកអាចទូរសព្ទទៅ **1800 560 870**។ សូមអនុញ្ញាតឱ្យពួកយើងដឹង ប្រសិនបើអ្នកត្រូវការអ្នកបកប្រែផ្ទាល់មាត់ ហើយយើងនឹងរៀបចំជូនអ្នកដោយឥតគិតថ្លៃ។ ប្រសិនបើអ្នកគ្រាន់តែចង់ដាក់ពាក្យសុំសម្រាប់បំណុលដែលមានសិទ្ធិមួយចំនួនរបស់អ្នក សូមទូរសព្ទមកលេខនេះ។

នៅពេលអ្នកដាក់ពាក្យសុំគ្រោងការណ៍ដំណោះស្រាយដោយជោគជ័យ
យើងនឹងផ្តល់ឱ្យអ្នកនូវបង្កាន់ដៃលេខសម្គាល់មួយ និងផ្ញើលិខិតបញ្ជាក់ដល់អ្នក។

យើងនឹងទាក់ទងអ្នកចាប់ពីខែកក្កដា ឆ្នាំ 2026 ដើម្បីឱ្យអ្នកដឹងថាអ្នកនឹងទទួលបានការទូទាត់ប្រាក់ និងចំនួនប៉ុន្មាន ឬក៏អត់។

យើងនឹងចំណាយពេលដើម្បីដំណើរការពាក្យសុំ និងការទូទាត់ប្រាក់ទាំងអស់។

អ្នកអាចជ្រើសរើសនិយាយថា បាទ/ចាស ឬទេ ចំពោះការផ្តល់ជូនការទូទាត់ប្រាក់សម្រាប់គ្រោងការណ៍ដំណោះស្រាយ។

វាសំខាន់ណាស់ដែលអ្នកផ្តល់ឱ្យយើងនូវអាសយដ្ឋានបច្ចុប្បន្នរបស់អ្នក គណនីធនាគារ និងព័ត៌មានលម្អិតទំនាក់ទំនង។

## តើគ្រោងការណ៍ដំណោះស្រាយប៉ះពាល់ដល់សិទ្ធិស្របច្បាប់របស់ខ្ញុំយ៉ាងដូចម្តេចដែរ?

ប្រសិនបើអ្នកទទួលយកគ្រោងការណ៍ដំណោះស្រាយសម្រាប់ការទូទាត់បំណុល
នោះអ្នកយល់ព្រមចំពោះចំណុចទាំងអស់ដូចខាងក្រោម៖

- ដើម្បីដោះលែងកុម្មុនវែល (Commonwealth) ពីការទទួលខុសត្រូវទាំងអស់សម្រាប់ការទាមទារនានា អំពីរបៀបដែលប្រាក់ចំណូលរបស់អ្នកត្រូវបានគណនាសម្រាប់បំណុលទាំងនោះ
- មិនត្រូវចាត់វិធានការ ឬបន្តផ្លូវច្បាប់ណាមួយដែលទាក់ទងនឹងការប្រើប្រាស់ income apportionment របស់ Commonwealth ក្នុងការបង្កើនបំណុលនោះ
- មិនស្វែងរកសំណងបន្ថែមទាក់ទងនឹងបំណុលនោះ។

ប្រសិនបើអ្នកមានការព្រួយបារម្ភណាមួយអំពីការទទួលយកការផ្តល់ជូនការទូទាត់ប្រាក់ ឬមានសំណួរនានា
យើងសូមណែនាំឱ្យអ្នកស្វែងរកដំបូន្មានផ្នែកច្បាប់។

ការដាក់សុំគ្រោងការណ៍ដំណោះស្រាយមិនប៉ះពាល់ដល់សិទ្ធិរបស់អ្នកក្នុងការត្រួតពិនិត្យ
ឬបណ្តឹងឧទ្ធរណ៍លើបំណុលរបស់អ្នកទេ។ នេះមានន័យថា
អ្នកនៅតែអាចស្នើសុំឱ្យមានការពិនិត្យឡើងវិញលើការសម្រេចចិត្តដើម្បីបង្កើន ឬទាម ទារបំណុលមកវិញ។

## សម្រាប់ព័ត៌មានបន្ថែម

- សូមចូលទៅកាន់ **servicesaustralia.gov.au/incomeapportionment** សម្រាប់ព័ត៌មានបន្ថែមជាភាសាអង់គ្លេស។
- ចូលទៅកាន់ **servicesaustralia.gov.au/yourlanguage** ជាកន្លែងដែលអ្នកអាចអាន ស្តាប់ ឬមើលព័ត៌មានជាភាសារបស់អ្នក។

- ទូរសព្ទទៅ 131 202 ដើម្បីនិយាយជាមួយយើងជាភាសារបស់អ្នក អំពីប្រាក់ឧបត្ថម្ភ និងសេវាកម្មនានារបស់ Centrelink។
- អញ្ជើញទៅកាន់មជ្ឈមណ្ឌលសេវាកម្ម។

ចំណាំ៖ ការហៅទូរសព្ទពីទូរសព្ទផ្ទះរបស់អ្នកទៅលេខ '13' ពីកន្លែងណាមួយនៅក្នុងប្រទេសអូស្ត្រាលី នឹងត្រូវបង់ថ្លៃតាមអត្រាថេរ។ អត្រានេះអាចខុសគ្នាពីអត្រាហៅទូរសព្ទនៅតាមតំបន់ និងរវាងក្រុមហ៊ុនផ្តល់សេវាកម្មទូរសព្ទនានា។ ការហៅទូរសព្ទទៅលេខ '1800' ពីទូរសព្ទផ្ទះរបស់អ្នកគឺមិនគិតថ្លៃទេ។ ការហៅទូរសព្ទពីទូរសព្ទសាធារណៈ និងទូរសព្ទដៃ អាចគិតថ្លៃតាមពេលម៉ោងហៅ ហើយគិតថ្លៃតាមអត្រាខ្ពស់ជាង។

## ការបដិសេធ

ព័ត៌មានដែលមាននៅក្នុងការបោះពុម្ពផ្សាយនេះ គឺមានគោលបំណងត្រឹមតែជាការណែនាំអំពីការទូទាត់ និងសេវាកម្មប៉ុណ្ណោះ។ វាជាទំនួលខុសត្រូវរបស់អ្នកក្នុងការសម្រេចចិត្តថាតើអ្នកចង់ដាក់ពាក្យសុំប្រាក់ឧបត្ថម្ភ និងធ្វើការដាក់ពាក្យឬអត់ ទាក់ទងនឹងកាលៈទេសៈជាក់លាក់របស់អ្នក។

# Income Apportionment Resolution Scheme

## Information about one-off payments for debts affected by income apportionment

If you have a debt which may be affected by income apportionment, you can apply for the Income Apportionment Resolution Scheme (the Resolution Scheme). You can check if you are eligible on page 2 of this factsheet.

A debt is any money you need to pay back to us.

You can apply from 30 January 2026 until 29 January 2027.

## What is income apportionment?

We used income apportionment to divide a customer's employment income evenly across 2 or more Centrelink fortnightly reporting periods. We only did this when both the following applied:

- your Centrelink reporting period did not line up with your employment pay period
- we did not have information about the days you worked or how much you earned in each Centrelink fortnight.

We based your payment rate on the total income you reported across those fortnights.

Since 7 December 2020, you only need to report income shown on your payslip in the same Centrelink fortnight you get paid.

This means we do not need to divide your income across fortnights to work out your payment rate for income earned after 7 December 2020.

On 5 December 2025, legislation came into effect to validate the use of income apportionment. This means that debts for income earned before 7 December 2020 will not be recalculated and may need to be repaid.

## What is the Resolution Scheme?

The Resolution Scheme offers compensation to people to recognise that income apportionment did not meet social security law at that time.

The Resolution Scheme is open to people whose employment income debts were affected by income apportionment between 20 September 2003 and 6 December 2020.

You need to apply to be eligible to get a one-off payment of up to $600. If you have more than one eligible debt, you can apply for a payment for each debt.

The amount of money you may get will depend on the total value of each debt on 30 January 2026. If you have already paid some of the debt, this will not affect the amount of your resolution payment.

| Total debt value | Resolution payment amount |
|---|---|
| Less than $200 | The full debt value |
| $200 – $1,999 | $200 |
| $2,000 - $4,999 | $400 |
| $5,000 or more | $600 |

Resolution payments will not be taxed and will not be counted as income for government payments.

## How do I know if I can get a resolution payment?

You may be eligible for the Resolution Scheme if all the following apply:

- your Centrelink debt is at least partly for a period between 20 September 2003 and 6 December 2020 and related to employment income
- your debt was affected by income apportionment and raised before 5 December 2025
- you have not been prosecuted and found guilty of fraud for your debt
- your debt has not been waived in full or set to zero before 30 January 2026.

You can still get a resolution payment even if you have paid part of the debt or the full amount.

You can check if your debt was affected by income apportionment and if you can get a resolution payment.

You can do this by using your Centrelink online account through myGov or the Express Plus Centrelink mobile app, and following these steps:

1. Go to the Money You Owe service.
2. Click 'Apply for Resolution Scheme' button.
3. If you have debts that might be eligible, they will show here.

If you do not a have a myGov or linked Centrelink online account, please call us on **1800 560 870**. You should also call this number if you cannot see a debt listed that you think should be eligible.

## How do I apply for the Resolution Scheme?

You can apply for the Resolution Scheme from 30 January 2026 until 29 January 2027.

You can apply for the Resolution Scheme online or by phone.

To apply online, you will need to use your Centrelink online account through myGov or the Express Plus Centrelink mobile app, and follow these steps:

1. Go to the Money You Owe service.
2. Click 'Apply for Resolution Scheme' button.
3. Select the debts you want to be considered for a resolution payment.

If you need help or want to apply over the phone, you can call **1800 560 870**. Let us know if you need an interpreter and we will arrange one for free. If you only want to submit an application for some of your eligible debts, please call this number.

When you successfully submit an application for the Resolution Scheme, we will give you a receipt ID and send you a confirmation letter.

We will contact you from July 2026 to let you know if you will get a payment and the amount.

It will take us time to process all applications and payments.

You can choose to say yes or no to the Resolution Scheme payment offer.

It is important that you give us your current address, bank account and contact details.

## How does the Resolution Scheme impact my legal rights?

If you accept a Resolution Scheme payment for a debt, you agree to all the following:

- to release the Commonwealth from all liability for claims about how your income was calculated for those debts
- not to take, or continue, any legal action in relation to the Commonwealth's use of income apportionment in raising that debt
- not to seek further compensation in relation to that debt.

If you have any concerns about accepting a payment offer, or have questions, we recommend that you get legal advice.

Applying for the Resolution Scheme does not affect your right to review or appeal your debt. This means that you can still ask for a review of the decision to raise or recover the debt.

## For more information

- Go to **servicesaustralia.gov.au/incomeapportionment** for more information in English.
- Go to **servicesaustralia.gov.au/yourlanguage** where you can read, listen to or watch information in your language.
- Call **131 202** to speak with us in your language about Centrelink payments and services.
- Visit a service centre.

Note: calls from your home phone to '13' numbers from anywhere in Australia are charged at a fixed rate. That rate may vary from the price of a local call and may also vary between telephone service providers. Calls to '1800' numbers from your home phone are free. Calls from public and mobile phones may be timed and charged at a higher rate.

## Disclaimer

The information contained in this publication is intended only as a guide to payments and services. It's your responsibility to decide if you wish to apply for a payment and to make an application with regard to your particular circumstances.